# សិលាចារឹកប្រាសាទភ្នំដាច់ (ភាគ ២)

ប្រាសាទភ្នំដាច់ មានទីតាំងស្ថិតនៅក្នុងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលជាប្រាសាទសាងសង់ឡើងនៅលើកូនភ្នំមួយ មានប្រាង្គចំនួន២ ធ្វើអំពីឥដ្ឋ បែរមុខទៅទិសខាងកើត តែប្រាង្គដែលនៅឈរមានរូបរាង គឺនៅសល់តែមួយប៉ុណ្ណោះ (មួយទៀតបាក់បែកអស់)។ នៅឆ្នាំ ២០២០ អ្នកស្រុកបានប្រមូលគ្នាមកកាប់ឆ្ការព្រៃកសាងវត្តអារាមមួយនៅលើភ្នំនេះ ក៏ប្រទះឃើញសិលាចារឹកចំនួន ២ ផ្ទាំង។ នៅភាគមុន យើងបានបង្ហាញអំពីសិលាចារឹកផ្ទាំងទី១ រួចមកហើយ ដូច្នេះនៅពេលនេះយើងនឹងពិភាក្សាបន្តអំពីសិលាចារឹកផ្ទាំងទី២ ដែលរកឃើញនៅភ្នំដាច់។

សិលាចារឹកនេះចារឹកនៅលើថ្មភក់ រាងជាបង្គោលសីមា អក្សរចារឹកបានជ្រៅល្អដែលផ្ទុយពីសិលាចារឹកផ្ទាំងទី១ ការចារឹកអក្សរមានសភាពរាក់ខ្លាំង។ ជាអកុសល សិលាចារឹកផ្ទាំងទី២នេះរងភាពខូចខាតជាច្រើន ដោយសារការប្រេះបែក នាំឱ្យអក្សរមានរលុបដោយអន្ទើ។ អត្ថបទនេះសរសេរបែបអក្សរជ្រៀងឃ្វាស ដែលមានលក្ខណៈពិបាកអាន។ សិលាចារឹកនេះបានបញ្ជាក់កាលប្រវត្តិច្បាស់លាស់ បើទោះបីជាអត្ថន័យពិបាកយល់ដោយសារការបាក់បែកក៏ដោយ។

ចំណុចដែលគួរឱ្យកត់សម្គាល់ខ្លាំងនៅក្នុងអត្ថបទសិលាចារឹកនេះ គឺឋានន្តរនាម "វាប" គេសរសេរថា "ពាបិ" ដែលហាក់បីដូចជាសំណេរប្លែកមួយនៅរវាងពាក់កណ្ដាលស.វ.ទី១០ ទោះបីសំណេររបៀបនេះឃើញមានច្រើននៅក្នុងសិលាចារឹកស.វ.ទី១១ក៏ដោយ (ឧទាហរណ៍ សិលាចារឹកគោកកន្ទាំង សិលាចារឹកគោកតាមាស ជាដើម) ដែលវាទំនងឆ្លុះបញ្ចាំងអំពីការប្រើប្រាស់គ្រាមភាសានៅក្នុងតំបន់នោះផងដែរ។ លើសពីនេះ ពាក្យ "គិពបាទ" និង "គិពលិង្គ" ក៏ជាសំណេរល្បៀងចេញពីសំណេរទូទៅក្នុងសិលាចារឹកនានាក្នុងពាក់កណ្ដាលស.វ.ទី១០ដែរ។ ជាទូទៅ ពាក្យថា "គិពបាទ" ឬ "គិរបាទ" ជាស្ថាននាមពេញនិយមមួយតាំងតែអំពីសម័យបុរាណកាលមក ដែលនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ស្ដីអំពីការគោរពទៅលើ ព្រះទ្វេបាទា ទាំងគូរបស់អង្គព្រះសិវ។ សិវបាទនេះមាននៅស្ថានទីជាច្រើនដូចជា តំបន់ភ្នំបាយង្កោ ព្រះនេត្រព្រះ ភ្នំពលសណ្ដក ប្រាសាទនាគបួស ប្រាសាទតាមាន់ធំ ប្រាសាទកំបុត ប្រាសាទតារស់ ប្រាសាទដូនកៅ ។ល។ ប៉ុន្តែស្ថិតនៅមិនឆ្ងាយប៉ុន្មានអំពីប្រាសាទភ្នំដាច់នេះ មានទេវស្ថានបុរាណមួយ ទំនងជាសាងសង់ឡើងដំបូងនៅក្នុងកំឡុងស.វ.ទី៨ មានឈ្មោះថា សិវបាទបូរ្វ ឬ សិវបាទបូព៌ ដូច្នេះស្ថាននាមនៅក្នុងសិលាចារឹកភ្នំដាច់នេះ ទំនងជាសំដៅដល់សិវបាទបូរ្វ ឬសិវបាទបូព៌ ឬឈ្មោះបច្ចុប្បន្នហៅថាប្រាសាទនាគបួសនោះឯង។ សិវបាទបូរ្វ ឬសិវបាទបូព៌ ឬឈ្មោះបច្ចុប្បន្នហៅថាប្រាសាទនាគបួសនោះមានទីតាំង

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*ស្ថិតនៅខាងកើតភ្នំកំពែង (ភ្នំដងរែក)។ ចំណែក ទេវស្ថានមួយទៀតស្ថិតនៅខាងលិចភ្នំដងរែក មានឈ្មោះថា សិវបាទបស្ចឹម ឬ សិវបាទខាងលិច ត្រូវនឹងឈ្មោះប្រាសាទតាមាន់ធំដែលយើងហៅសព្វថ្ងៃ។*

*ចំណែកឯ ពាក្យថា គិពលិង្គ ឬ សិវលិង្គ ក៏ជាស្ថាននាមមួយដែរ កាលស.វ.ទី១១ សិវលិង្គ ឬ កម្រតេងអញសិវលិង្គ ជាទេវស្ថានមួយដែលតម្កល់ព្រះលិង្គ ប៉ុន្តែដោយសារស្ថាននាមនេះមានឈ្មោះដូចគ្នាច្រើនទើបសិលាចារឹកមួយចំនួនដូចជា សិលាចារឹកវត្តប្រាសាទពជាសំពោង* K.1198 *បានបញ្ជាក់បន្ថែមដោយប្រើពាក្យថា គិវលិង្គ អាយ មទ្យទេគ (សិវលិង្គ នៅឯមទ្យទេស)។ ទោះយ៉ាងណាតាមរយៈសិលាចារឹកភ្នំដាច់នេះ ព្រះកម្រតេង អញ គិពលិង្គ ឬ សិវលិង្គ សម្តៅដល់ទេវស្ថានភ្នំដាច់នេះតែម្តង។*

*អត្ថន័យទូទៅរបស់សិលាចារឹកភ្នំដាច់ផ្ទាំងទី២នេះ រៀបរាប់ទាក់ទងទៅនឹងមន្ត្រី ឬអាចជាព្រាហ្មណ៍បព្វជិតជាន់ខ្ពស់ណាម្នាក់ ដែលមានគោរមងាររថា ព្រះកម្រតេងអញ បានចូលទៅគាល់និងទូលថ្វាយព្រះមហាក្សត្រ ដើម្បីស្នើសុំសិទ្ធិដោយរាជានុគ្រោះអំពីព្រះមហាក្សត្រ ស្តីអំពីការធ្វើអំណោយបុណ្យដល់ទេវស្ថាន និងការចារឹកសិលាទុកជាកស្តុតាងផង ហើយអំណោយទាំងអម្បាលម៉ានមានបុព្វសិទ្ធិពិសេសមិនស្ថិតនៅក្រោមអាជ្ញាធម៌ថ្នាក់ក្រោមជាតិឡើយ។*

**អត្ថបទពាក្យចារឹក**

១. ៨៨៥

២. ..កកាចៃត្រ...ប្រតិមា ណាអញយ.........

៣. ...ព្រះកម្រតេងអ៊ី[អញ] បង្គុំ ថ្យ្វង៑ និវេទន សុំ .....ព្រះក

៤. រុណា ប្រសាទ បិ និវេទន ត កម្រតេង៑ ជកត្តាវជ្យ មាន ព្រះករុណា

៥. ..អញ ទ្វលិ ព្រះ គាសន ស្តេង៑ អាចាយ៌្យ សេនាបតិ ទុ ស្តេង៑ អាចា

៦. យ៌្យ កុណាតោមទគ៌ិ ប្រៃ ឱយ៑ កុមិ ទុ.... ទៅ ឱយ ពោ

៧. ហ....អាចាយ៌្យ ស្វំម ស្តេង៑ សេនា បតិ ទុ ស្តេង៑[អញ អាចា]

៨. ចាយ៌្យ កុណាតោមទគ៌ិ ឧយ្យ៌្វត្យយិ ផ្ទះ ៣៧ ពក្តារ គិពទៅ

៩. សង៑ ប្រកស្ត ត តិ ស្រេ អមនិពោហ មនិ អាចាយ៌្យ..ត នេះ

១០. ....ព្រះ រាជ បុន្យ ពុំ ជា សុតន្ត្រ ត ខ្ញោញ៑ កាន្ទ្វារ ពុំ ជា បិ នារ

១១. ប្រិង៑ ពុំ ជា បិ អាចាយ៌្យ ៤ ត តិ ស្រុក៑ ជា ...ជយ...

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

១២. ...ងា ស្តេងី អាចាយ៌្យ ជគត ត ព្រះ កម្រតេងីអញ ត រាជ្យ

១៣. ..ប្រស្ថ...ប្រតិជិង ខ្ញុំ៣ក្រាបិ៤ ថ្នរ៑

១៤. កម្រតេង៑ ជគត គិព ចាង តន្ទុល ប្រស្ថ ៩ ប្រតិជិង បុប្ប...

១៥. .....ទេព......ព្រះ កម្រតេងីអញ គិពលិង្គ ប្រតិជិង

១៦. ទ្រោណ៤ .....៚

**បំណកប្រែ**

*(១-៩) នៅមហាសករាជឆ្នាំ៨៨៥ ខែចេត្រ ....ប្រតិមា ....ព្រះកម្រតេង៑ [អញ] បានចូលទៅក្រាបថ្វាយបង្គំ ទូលថ្វាយព្រះមហាក្សត្រ ដើម្បីសូម.....ព្រះករុណាព្រះរាជប្រទាន ត្រាស់បង្គាប់ដល់កម្រតេង៑ជគត្តរាជ្យ ព្រះមហាក្សត្រ។ ព្រះករុណា ទូលសាសន៍ (សេចក្តីណែនាំ) ដល់ស្តេង៑អាចាយ៌្យសេនាបតី និង៑ស្តេង៑អាចារ្យ គុណទោបទគិ៑ (អ្នកមើលការខាង៑គុណ និង៑ទោស) ត្រាស់បង្គាប់ប្រើឱ្យប្រគល់ដីភូមិ និង៑.... ទៅឱ្យ....អាចារ្យ ហើយសូមឱ្យស្តេង៑សេនាបតិ និង៑ស្តេង៑អញអាចារ្យគុណទោបទគិ៑ ដើម្បីឱ្យប្រគល់ប្រត្រយ (ជំនិត ឬអ្នកដែលអាចទុកចិត្តបាន) ម្នាក់ឈ្មោះ ពាព ពក្តវគិព (វាប វក្តវសិវ) ឱ្យទៅសង់ប្រសស្ត (គោលចារឹក) ។*

*(៩-១៣) ដីស្រែ អមនិរោហ ដែលអាចារ្យ ..ទាំងនេះ....ព្រះរាជបុណ្យពុំស្ថិតនៅក្រោមអាជ្ញាធម៌ឡើយ ដូចជា ខ្ញោញកន្ទារ មិនអាចទារយកនូវប្រេង ពុំដើម្បីសម្រាប់អាចារ្យ ៤ ដែលនៅស្រុក នា ...ជយ...នា ស្តេង៑អាចារ្យជគត ដែលជាព្រះកម្រតេង៑អញតរាជ្យ...ចំនួន...ប្រស្ថ..អ្នកបម្រើជាប្រចាំថ្ងៃ២នាក់ ក្របី ៣ក្បាល គោ...។*

*(១៤-១៦) តង្វាយដល់កម្រតេង៑ជគតគិពបាទ (សិវបាទ) មាន តន្ទុល (អង្ករ) ចំនួន៩ ប្រស្ថជាប្រចាំ ..បុប្ប (ផ្កា).....ទេព......និង៑តង្វាយសម្រាប់ព្រះកម្រតេង៑អញសិពលិង្គ (សិវលិង្គ) មាន ៤ ទ្រោណជាប្រចាំថ្ងៃ....។*

*ជារួមមក អត្ថន័យសិលាចារឹកភ្នំដាច់ផ្ទាំង៑ទី២នេះ គឺរៀបរាប់ព្រឹត្តិការណ៍នៅមហាសករាជឆ្នាំ៨៨៥ ដែលស្ថិតក្រោយព្រឹត្តិការណ៍សិលាចារឹកផ្ទាំង៑ទី១ចំនួន ៣ ឆ្នាំ។ ប៉ុន្តែ អត្ថន័យជារួម គឺមិនខុសឃ្លាតគ្នាប៉ុន្មានឡើយ ពោល គឺការសុំរាជានុញ្ញាតពីព្រះមហាក្សត្រដើម្បីត្រាស់បង្គាប់បញ្ជាមន្ត្រីយកតង្វាយទៅថ្វាយទេវស្ថាន និង៑ការសាង៑សង់គោលចារឹក៕*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ ប្រាសាទភ្នំដាច់ តួប៉មទី១ មើលពីទិសខាងកើត



រូបលេខ២៖ ប្រាសាទភ្នំដាច់ តួប៉មទី១ មើលពីទិសខាងលិច

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ២៣៖ គ្រឹះប្រាសាទតូចមួយទី២ នៃប្រាសាទភ្នំដាច់



រូបលេខ២៤៖ គោលសិលាចារឹកផ្ទាំងទី២ រកឃើញនៅប្រាសាទភ្នំដាច់

អត្ថបទដោយ៖ កំ វណ្ណាវ៉ា



រូបលេខ៩៖ ក្រដាសផ្តិតសិលាចារឹកផ្ទាំងទី២ នៃប្រាសាទភ្នំដាច់ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា